01324627

E437

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-Sep-2016, 14:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ អមដោយ **ឯកសារភ្ជាប់សាធារណៈ:១**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកឯកសារមួយ

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្ដារ

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ:**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**

លោកស្រី ទូច វល័ក្ស

លោក Calvin SAUNDERS

# I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន៨៧ (៣) និង (៤) នៃវិធានផ្ទៃក្នុង[1] សហព្រះរាជអាជ្ញាដាក់ញត្តិនេះ ស្នើសុំឱ្យមានការទទួលយកជាភ័ស្តុតាងនូវឯកសារមួយ ដែលជារបាយការណ៍បេសកកម្មការទូតរបស់អតីតៈសាធារណៈរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ("GDR") ក្នុងទីក្រុងវៀងចាន់ នៃសាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ("ឡាវ") កាលបរិច្ឆេទខែតុលា ឆ្នាំ១៩៧៧ ("ឯកសារ")[2]។

# II. សេចក្តីសន្និដ្ឋាន

២. អង្គជំនុំជម្រះនេះបានបញ្ជាក់នាពេលថ្មីៗនេះអំពីច្បាប់ជាធរមានពាក់ព័ន្ធនឹងការទទួលយកភ័ស្តុតាងថ្មីថាៈ

> អង្គជំនុំជម្រះរម្លឹកថា អនុលោមតាវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងកំឡុងពេលសវនាការអង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះក៏ស្របទៅនឹងបទដ្ឋាននៃភាពពាក់ព័ន្ធ ភាពជឿជាក់បាន និង យថាភាព *តាមការវិភាគបឋម*អនុលោមតាមវិធាន ៨៧(៣)។ អង្គជំនុំជម្រះធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏តម្រូវថា គ្រប់ភាគីដែលបានស្នើសុំទទួលយកភ័ស្តុតាងថ្មីត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ឬមិនអាចរកឃើញបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់សមស្របរួចហើយ។ ក៏ប៉ុន្តែនៅក្នុងករណីមួយចំនួនអង្គជំនុំជម្រះបានទទួលយកជាឯកសារភ័ស្តុតាងផងដែរ បើទោះបីជាឯកសារនោះមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងនេះក៏ដោយ រួមមានករណីភ័ស្តុតាងនោះជាប់ពាក់ព័ន្ធជាមួយសម្ភារៈ ដែលមាននៅចំពោះមុខអង្គជំនុំ

---

[1] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិ. ៩, ១៦ មករា ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន")។

[2] ឯកសារ មានចំណងជើង "Zur Situation in der Partei- und Staatsführung des Demokratischen Kampuchea" ("អំពីស្ថានភាពក្នុងបក្ស និងថ្នាក់ដឹកនាំរដ្ឋកម្ពុជាប្រជាធិបតេយ្យ"), ត្រូវបានភ្ជាប់ទៅនឹងញត្តិនេះក្នុង **ឯកសារភ្ជាប់លេខ១**។

ជម្រះរួចហើយ និងក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃរួមគ្នាលើប្រភពនៃភ័ស្តុតាងទាំងនោះ ...[3]

៣. សហព្រះរាជអាជ្ញាយល់ឃើញថាសម្រាប់ហេតុផលនានាខាងក្រោមនេះ ឯកសារនេះពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ អាចជឿជាក់បាន និងមានយថាភូត និងជួយដល់ការស្វែងរកការពិត។ ឯកសារនេះសហព្រះរាជអាជ្ញាមិនអាចរកបាននៅមុនពេលនៃការបើកការជំនុំជម្រះ ហើយហេតុដូច្នេះ គួរត្រូវបានទទួលយកដើម្បីផលប្រយោជន៍យុត្តិធម៌។ ដោយសារតែភាសាដើមរបស់ឯកសារនេះជាភាសាអាល្លឺម៉ង់ ហើយវាមិនទាន់ត្រូវបានបកប្រែជាភាសាផ្លូវការណាមួយនៃអង្គជំនុំជម្រះនេះ សហព្រះរាជអាជ្ញាសូមផ្តល់ជូននូវសេចក្តីសង្ខេបខ្លឹមសារពាក់ព័ន្ធខាងក្រោម។

៤. សហព្រះរាជអាជ្ញាយល់ឃើញថាឯកសារនេះបំពេញលក្ខណៈវិនិច្ឆ័យ *បឋម* សម្រាប់ការទទួលយកដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ឯកសារនេះចុះកាលបរិច្ឆេទថ្ងៃទី ៣-៤ ខែតុលា ឆ្នាំ១៩៧៧ និងមានរបាយការណ៍មួយ ដែលទំនងជាត្រូវបានរៀបចំឡើងដោយក្រសួងការបរទេសរបស់ GDR តាមរយៈបេសកកម្មការទូតរបស់ខ្លួននៅក្នុងទីក្រុងវៀងចាន់ប្រទេសឡាវ។ វាកត់ត្រាព័ត៌មានដែលបានផ្តល់ឱ្យដោយ ឯកអគ្គរដ្ឋទូតសាធារណៈរដ្ឋសង្គមនិយមវៀតណាម (“វៀតណាម”)។ ដោយសារតែប្រភពរបស់វាស្ថិតនៅក្នុងបណ្ណាសារផ្លូវការដែលអាចចូលមើលបានជាសាធារណៈរបស់ក្រសួងការបរទេសអាល្លឺម៉ង់[4] ឯកសារនេះមានយថាភាពតាមការសន្មត។ ជាពិសេសនោះ ខ្លឹមសាររបស់វាអាចជឿជាក់បាន ដោយសារតែឯកសារនេះមិនមានគោលបំណងសម្រាប់ការប្រើប្រាស់ជាសាធារណៈនោះទេ ប៉ុន្តែបានបង្កើតបានជាផ្នែកមួយនៃទំនាក់ទំនងផ្ទៃក្នុងនៅក្នុងប្លុកសម្ព័ន្ធមិត្តកុម្មុយនីស។

៥. ឯកសារនេះពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ជាពិសេសក្នុងការច្រានចោលការអះអាងរបស់ នួន ជា ដែលថាក្រុមជម្លោះនៅក្នុងបក្សកុម្មុយនីសកម្ពុជា (“ប.ក.ក”) “បានទទួលការគាំទ្រជាច្រើនពីវៀតណាមដើម្បីបង្កការបះបោរ និងអនុវត្តអំពើក្បត់ប្រឆាំងនឹង[...]

---

[3] **E390/2** ស្តីពី៖សេចក្តីសម្រេចលើសំណើលើកទី១ របស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំកោះហៅ សាក្សីបន្ថែមមួយរូប និងទទួលយកកិច្ចសម្ភាសន៍មួយសម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោលនៃសំណុំរឿង ០០២/០២, ៤ ឧសភា ២០១៦, កថាខណ្ឌ ៣។

[4] ឯកសារនេះត្រូវបានដកស្រង់ចេញពីឯកសារ MfAA – C 6682, មានចំណងជើងថា “Berichte und Informationen von Botschaften der DDR in Vietnam und China sowie kambodschanische Dokumente zur Lage in Kampuchea” (“របាយការណ៍ និងព័ត៌មានរបស់ ស្ថានទូត GDR ក្នុងប្រទេសវៀតណាម និងចិន ព្រមទាំងឯកសារកម្ពុជា អំពីស្ថានភាពនៅកម្ពុជា”) ពីបណ្ណាសារនយោបាយរបស់ក្រសួងការបរទេស ក្នុងទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់។

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ”[5]។ នួន ជា បានអះអាងថា “ផែនការ ៥ របស់វៀតណាមគឺ ឧបត្ថម្ភ ហ្វឹកហ្វឺន និងដាក់ជាអាយ៉ងនូវជនកម្ពុជាដែលជាតំណាងរបស់ខ្លួនដើម្បីត្រួតត្រាផ្ទៃក្នុងប្រទេស តាមរយៈការបះបោរ និងរដ្ឋប្រហារ ព្រមទាំងសកម្មភាពវិទ្ធង្សនានានា”[6]។ ខៀវ សំផន បានដាក់ជូននូវអំណះអំណាងស្រដៀងគ្នានេះដែរ[7]។ សម្រាប់ហេតុផលនានាដូចដែលបានរៀបរាប់ដោយសហព្រះរាជអាជ្ញា ភស្តុតាងនៃក្រុមជម្លោះ ឬការបះបោរនានាប្រឆាំងនឹងថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ (“DK”) មិនពាក់ព័ន្ធផ្លូវច្បាប់ទៅនឹងសំណុំរឿង ០០២/០២ នោះទេ ហើយនឹងមិនធ្វើឱ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដែលពួកគេត្រូវបានចោទប្រកាន់នោះឡើយ[8]។ ឯកសារនេះបង្ហាញថា មុខតំណែងរបស់ជនជាប់ចោទក៏មិនត្រឹមត្រូវពិតជាក់ស្តែងនោះដែរ។

៦. ឯកសារបង្ហាញថាប្រភពការទូតវៀតណាមដែលបានពន្យល់ពីការយល់ដឹងរបស់ខ្លួនអំពីរចនាសម្ព័ន្ធដឹកនាំនៅក្នុង បកក នៅចុងឆ្នាំ១៩៧៧។ លោកអគ្គរដ្ឋទូតវៀតណាមរាយការណ៍ពីអត្ថិភាពនៃក្រុមជម្លោះចំនួនពីរនៅក្នុងបក្សដឹកនាំ បកក ដោយបានពន្យល់ថាបក្សមួយដឹកនាំដោយ ប៉ុល ពត និង

---

5 **E395/2** សេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាងស្តីពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២, ១០ មិថុនា ២០១៦ (“សារណារបស់ នួន ជា អំពីការបះបោរ”), កថាខណ្ឌ១០។

6 **E395/2** សារណារបស់ នួន ជា អំពីការបះបោរ, កថាខណ្ឌ ១២។

7 សូមមើល ឧ. **E3/203** ប្រតិចារឹកនៃការសួរចម្លើយ ខៀវ សំផន, ENG 00424013-00424014, FR 00434232-00434233, KH 00385409-11, ជាពិសេស “បញ្ហាវាប៉ះពាល់ [អាយុប្រជាជនស្លូតត្រង់] មានដែរ នឹងមានសូមបញ្ជាក់គឺដោយភ្នាក់ងារ យួន ភ្នាក់ងារដែលខ្មែរៗជាភ្នាក់ងារយួនបង្កប់នៅក្នុងជួររដ្ឋអំណាចយើងខ្ញុំ ហើយមានតួនាទីសំខាន់ៗ **[...]** កាលពីសង្គ្រាមឥណ្ឌូចិនលើកទីមួយ លោកប្រហែលជាអាចជ្រាប។ មានកម្មាភិបាល និងកងទ័ពយៀកមិញធ្វើសកម្មភាពនៅកម្ពុជា ដែលវាក្តាប់ចលនាតស៊ូនៅកម្ពុជាគឺពេលហ្នឹងហើយដែលវាកសាងភ្នាក់ងាររបស់វាសម្រាប់បម្រើយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់វា។ តាំងពីនោះមក ហើយតាំងពីនោះមក ពីមួយឆ្នាំទៅមួយឆ្នាំវាចេះតែមាននាទីសំខាន់ៗ ហើយវាបង្កប់ខ្លួននៅក្នុងចលនាយើងខ្ញុំ។ គឺពួកនេះ ដល់ពេល ៧៥ វាមាននាទីសំខាន់វិញ វាប្រើនាទីសំខាន់ហើយអ្នកខ្លះកាន់ភាគអំណាចសំខាន់ៗដើម្បីបំផ្លើសមាគ៌ាយើងខ្ញុំ **[...]** ពួកអស់ហ្នឹងនៅហ្នឹង ពួកនេះជាភ្នាក់ងារយួនបម្រើយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់យួន [...] វាសម្រេចៗ ហើយជាបន្តបន្ទាប់មកគឺវាចេះតែមាននាទីសំខាន់ឡើងៗ។ ដល់ពេល៧៥, ៧៨ វាធ្វើសកម្មភាព។ [...] សៈ បើឆ្នាំ៧៥ បើនិយាយពីឆ្នាំ ៧៥ វានិយាយពីថ្នាក់លើរបស់បក្ស ក្នុងគណៈមជ្ឈិម ឬក្នុងគណៈអចិន្ត្រៃយ៍ របស់មជ្ឈិមពួកហ្នឹងមានប្រហែលជាប៉ុន្មានភាគរយ? ឆៈ មានច្រើន។ សៈ ដល់ពាក់កណ្តាលទេ? ឆៈ គឺក្នុងមជ្ឈិមមិនដល់ពាក់កណ្តាលទេ។ ប៉ុន្តែ ក្នុងអចិន្ត្រៃយ៍វាជិតពាក់កណ្តាល។”

8 សូមមើល **E395/3** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីសន្និដ្ឋានរបស់ នួន ជា ស្តីពីក្រុមជម្លោះ និងការបះបោរដែលបានចោទឡើងនៅអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ, ២០ មិថុនា ២០១៦។

អៀង សារី ដែលជា "ចុល្លគហបតីនិយម ឧកាសនិយម និង ប្រឆាំងនឹងវៀតណាម" ដែលមុខតំណែងរបស់ពួកគាត់ ដែលគាត់មានយោបល់ផ្ទុយប្រកបដោយអត្តចរិក "សមហេតុសមផល" ជាងចំពោះ នួន ជា និង ខៀវ សំផន ដែលជា "សមមិត្តចាស់របស់ ហូ ជីមិញ" នៃវៀតណាម។

៧. ដូច្នេះ ការអានដ៏សមហេតុសមផលនៃឯកសារនេះបង្ហាញពីអវត្តមានរបស់ភ្នាក់ងារវៀតណាមនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ឬការគាំទ្ររបស់វៀតណាមចំពោះក្រុមជម្លោះដែលជំទាស់ទៅនឹងជនជាប់ចោទនៅក្នុងករណីនេះ។ វាបង្ហាញថា បើសិនជារបបវៀតណាមត្រូវបានពិចារណាថាត្រូវលើកស្ទួយបុគ្គល ឬ ក្រុម*ណាមួយ* នៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅចុងឆ្នាំ១៩៧៧ វាត្រូវតែជា នួន ជា និង ខៀវ សំផន ដែលពួកគាត់ទាំងនេះត្រូវបានគេពិចារណាថាជាសមាជិកនៃ បកក យ៉ាងមានមិត្តភាពបំផុតចំពោះវា។ ដូច្នេះ វៀតណាមបានមើលឃើញថាជាសម្ព័ន្ធមិត្តសក្តានុពលនូវបុគ្គលទីមួយៗ ដែលឥឡូវនេះអះអាងនៅក្នុងកិច្ចការពាររបស់ពួកគាត់ថា ពួកគាត់បានធ្វើការបោសសម្អាតតំបន់នានាទាំងស្រុងនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងគោលបំណងដើម្បីសម្លាប់ពួកដែលបានធ្វើសហការជាមួយនឹងវៀតណាម។ គ្រប់ភាគីទាំងអស់នៅក្នុងសវនាការបច្ចុប្បន្ននេះ ទំនងជាយល់ព្រមថាភស្តុតាងគឺគ្មានលក្ខខណ្ឌដែលថា នួន ជា និង ខៀវ សំផន មិនមែនជាអ្វីនោះទេ ប៉ុន្តែជាអ្នក "គាំទ្រវៀតណាម"។ អាស្រ័យហេតុដូច្នេះ ឯកសារនេះក៏បានបង្ហាញផងដែរពីកង្វះខាតទាំងស្រុងនៃពត៌មានច្បាស់លាស់ ដែលអាចមានបានចំពោះវៀតណាមអំពីការងារផ្ទៃក្នុងរបស់ បកក និងធ្វើឲ្យអស់សំណើចដល់ការអះអាងរបស់ជនជាប់ចោទដែលថាមានក្រុមជម្លោះនៃ បកក ដែលបានធ្វើការជាសម្ងាត់ឲ្យវៀតណាម។

៨. ចុងបញ្ចប់ វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ចែងថាភាគីដែលស្នើសុំឲ្យដាក់ភស្តុតាងថ្មីត្រូវតែឲ្យស្របតាមអង្គជំនុំជម្រះដែលថាភស្តុតាងស្នើសុំគឺមិនអាចរកបានទេនៅមុនការបើកសវនាការ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាចំពោះសំណុំរឿង០០២/០២ ការបើកសវនាការបានកើតឡើងនៅខែមិថុនា ឆ្នាំ២០១១[9]។ ឯកសារនេះត្រូវបានផ្តល់ឲ្យសហព្រះរាជអាជ្ញានៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ហើយដូច្នេះ វាមិនអាចរកបានទេនៅមុនការបើកសវនាការ។ លើសពីនេះ តាមទស្សនៈនៃភាពទាក់ទងរបស់វា ដូចដែលបានដាក់នៅក្នុងទម្រង់ខាងលើ ដើម្បីជំទាស់ទៅនឹងគោលជំហរ

---

[9] **E307/1** សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3), ១១ មិថុនា ២០១៤ កថាខណ្ឌ២។ **E307/1/2** សេចក្តីសម្រេចលើសំណើសុំរួមឲ្យសម្រេច*សាជាថ្មីឡើងវិញ* លើការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង, ២១ តុលា ២០១៤, កថាខណ្ឌ១០។

ដែលបានស្តែងឡើងដោយ នួន ជា នៅក្នុងការដាក់ជូនរបស់គាត់កាលពីខែមិថុនា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញា ជូនសេចក្តីសន្និដ្ឋានថា វាជាផលប្រយោជន៍នៃយុត្តិធម៌ចំពោះឯកសារ ដែលត្រូវបានទទួលយក។

## III. ដំណោះស្រាយដែលស្នើឡើង

៩. ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមគោរពស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងទទួលយកនូវឯកសារនេះ ដោយអនុលោមតាមវិធាន៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |